ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា
ចូល
លេខ 1319 ន.ទ.ក
ថ្ងៃទី 24 ខែ 06 ឆ្នាំ២០ 19
ម៉ោង 14:30 បញ្ជូន

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ ២០០ បទ

# សេចក្តីណែនាំ
# ស្តីពី
# ការបំពាក់ស្លាកសញ្ញានៅតាមស្ថានីយ៍ទូរស័ព្ទចល័ត អចល័ត និងខ្សែកាប្លិ៍ទូរគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

**យោង** ៖ - ព្រះរាជក្រម នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧ ច្បាប់ស្តីពីទូរគមនាគមន៍
- សេចក្តីណែនាំលេខ១៥១ បទ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- លិខិតលេខ០៣៤៥ ប.ក.ទ.ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ របស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជម្រាបជូនដល់បណ្តាប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ឱ្យបានជ្រាបថាៈ កន្លងមកបញ្ញត្តិករទូរគមនាគមន៍កម្ពុជា (TRC) បានចេញសេចក្តីជូនដំណឹងលេខ០៣៤៥ ប.ក.ទ.ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រងទីតាំងស្ថានីយ៍ Base Transceiver Station (BTS) ទូរស័ព្ទចល័ត អចល័តឥតប្រើប្រាស់ខ្សែ អាថ្វាបណ្ឌប្រេ្វកង់សម្រាប់ប្រើប្រាស់វិទ្យុម៉ៃក្រូវ៉េវ និងការស្ថាបនាបណ្តាញកាប្លិ៍ទូរគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ រហូតមកដល់ពេលនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សង្កេតឃើញថា មានប្រតិបត្តិករទូរគមនាគមន៍មួយចំនួនបានយកចិត្តទុកដាក់អនុវត្តដោយបំពាក់ស្លាកសញ្ញានៅតាមទីតាំងស្ថានីយ៍ Base Transceiver Station (BTS) និងខ្សែកាប្លិ៍ទូរគមនាគមន៍របស់ខ្លួនបានត្រឹមត្រូវប៉ុន្តែប្រតិបត្តិករទូរគមនាគមន៍មួយចំនួនទៀតនៅពុំទាន់បានអនុវត្តតាមសេចក្តីណែនាំ និងសេចក្តីជូនដំណឹងរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជានៅឡើយ។

ដូចនេះដើម្បីរក្សាសន្តិសុខជាតិ របៀបរៀបរយសាធារណៈ កំណត់ចំនួនឧបករណ៍ប្រើប្រាស់ឱ្យបានត្រឹមត្រូវ និងដើម្បីចូលរួមការអនុវត្តច្បាប់ទូរគមនាគមន៍ ឱ្យមានប្រសិទ្ធភាព ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍សូមធ្វើការណែនាំដូចខាងក្រោម៖

១. ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ត្រូវសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីបំពាក់ស្លាកសញ្ញាសម្គាល់ដោយបញ្ជាក់ពីនាមករណ៍ក្រុមហ៊ុន អាសយដ្ឋាន និងលេខទូរស័ព្ទ ឱ្យបានត្រឹមត្រូវនៅតាមទីតាំងស្ថានីយ៍ Base Transceiver Station (BTS) របស់ទូរស័ព្ទចល័ត អចល័តឥតប្រើប្រាស់ខ្សែ និងបំពាក់លើខ្សែទទួល ឬបញ្ជូនស៊ីញ៉ាល់របស់ឧបករណ៍វិទ្យុម៉ៃក្រូវ៉េវ ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ប្រតិបត្តិករទូរគមនាគមន៍ ត្រូវធ្វើបច្ចុប្បន្នភាពនូវចំនួនបង្គោលអង់តែន Base Transceiver Station (BTS) និងចំនួនម៉ៃក្រូវ៉េវរបស់ខ្លួនទាំងអស់ឱ្យបានច្បាស់លាស់ រួចបញ្ជូនមកនិយ័តករទូរគមនា-គមន៍កម្ពុជា និងចម្លងជូនអគ្គាធិការដ្ឋាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

៣. ប្រតិបត្តិករទូរគមនាគមន៍ ត្រូវធ្វើការបំពាក់ស្លាកសញ្ញាសម្គាល់នាមករណ៍ក្រុមហ៊ុន លេខទូរស័ព្ទទំនាក់ទំនងនៅជាប់នឹងខ្សែកាប្លិ៍របស់ខ្លួនដែលបំពាក់លើបង្គោលអគ្គិសនី ឬបង្គោលទូរស័ព្ទ និងទូប្រអប់ចែកចាយក្បាលកាប្លិ៍ (Telecom Cable, Cabinet, ODF, Splitter, DP, DLC ...etc) ដែលស្ថាបនាទូទាំងព្រះរាជាណាចក្រកម្ពុជា។

ទទួលបានសេចក្តីណែនាំនេះ សូមប្រតិបត្តិករទូរគមនាគមន៍ ព្រមទាំងបុគ្គលពាក់ព័ន្ធទាំងអស់ ចូលរួមសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។ ក្នុងករណីមិនអនុវត្តតាម ខ្លឹមសារនៃសេចក្តីណែនាំខាងលើ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមាន៕

ថ្ងៃចន្ទ ១៥កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩
រដ្ឋមន្ត្រី

ត្រាំ អុីវតិក

**ចម្លងជូន៖**
- -ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- -អគ្គនាយកដ្ឋានរដ្ឋបាល «ដើម្បីជ្រាប»
- -សាលារាជធានី.ខេត្ត
- -និយ័តករទូរគមនាគមន៍កម្ពុជា
- -មន្ទីរប.ទខេត្ត «សហការអនុវត្ត»
- -ប្រតិបត្តិករទូរគមនាគមន៍ «ដើម្បីអនុវត្ត»
- -ឯកសារ កាលប្បវត្តិ